អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០១១*

# សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេត

**ដោយពិនិត្យឃើញការភ័ន្តច្រឡំមួយចំនួនដែលមាននៅក្នុងអត្ថបទដែលមានចំណងជើងថា “Cambodia’s troubled tribunal” ដែលបានចុះផ្សាយនៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ ក្នុង International Justice Tribune ក៏ដូចជាការភ័ន្តច្រឡំផ្សេងទៀតដែលមាននៅក្នុងអត្ថបទសារព័ត៌មាននានា សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក. សូមធ្វើការបំភ្លឺដូចខាងក្រោម៖**

១. ពាក់ព័ន្ធនឹងការចោទប្រកាន់ដែលថា “*សហចៅក្រមស៊ើបអង្កេតកំពុងគំរាមសហព្រះរាជអាជ្ញាអន្តរជាតិជាមួយនឹងបទល្មើសនៃការប្រមាថតុលាការ*”៖ សហចៅក្រមស៊ើបអង្កេតមិនធ្លាប់បានធ្វើការគំរាមយ៉ាងដូច្នេះឡើយ ហើយក៏មិនធ្លាប់មានសកម្មភាពបង្ហាញថា សហចៅក្រមស៊ើបអង្កេតកំពុងពិចារណាអំពីបញ្ហានោះដែរ ។ ការចោទប្រកាន់ខាងលើនេះគ្រាន់តែជាពាក្យចចាមអារ៉ាមដែលមានគំនិតព្យាបាទធ្វើឡើងក្នុងគោលបំណងដើម្បីរំខានដល់ការសហការល្អនៅក្នុងតុលាការតែប៉ុណ្ណោះ ។

២. ចំពោះការលើកឡើងដែលថា “*ជាមួយនឹងស្ថានភាពវិបត្តនេះ តុលាការកំពុងធ្វើដំណើរឆ្ពោះទៅរកការបែកបាក់មួយដែលមិនអាចស្រោចស្រង់បាន*”៖ ដោយហេតុថាអង្គជំនុំជម្រះតុលាការកំពូលបានជំនុំជម្រះលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០១ និងអង្គជំនុំជម្រះសាលាដំបូងបានកំណត់យកពេលវេលាសម្រាប់រៀបចំសវនាការបឋមនៅក្នុងសំណុំរឿង ០០២ ចាប់ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ហើយដោយហេតុថាអង្គបុរេជំនុំជម្រះបានដំណើរការដោយជោគជ័យចំពោះការងារជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ដែលមានចំនួនច្រើនជាង ១៧០០ និងម្យ៉ាងទៀតដោយហេតុថាការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញាកំពុងបន្តបំពេញការងារជាធម្មតា (ទោះបីជាមានការខ្វែងយោបល់គ្នាលើទិដ្ឋភាពមួយចំនួនក៏ដោយ) ការលើកឡើងដែលថា តុលាការកំពុងធ្វើដំណើរឆ្ពោះទៅរកការប៉ះទង្គិចមួយដែលមិនអាចស្រោចស្រង់បានគឺជាការលើកឡើងដែលមិនមានមូលដ្ឋានត្រឹមត្រូវឡើយ។

៣. ការលើកឡើងដែលថា “*តុលាការកំពុងស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ជិតដួលរលំ*” និង “*អនាគតរបស់តុលាការកំពុងស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់*” គឺមិនមានលក្ខណៈត្រឹមត្រូវនិងសមស្របនឹងស្ថានភាព ពិតនោះឡើយ ។

សហចៅក្រមស៊ើបអង្កេតបាននិងបំពេញការងាររបស់ខ្លួនដោយឯករាជ្យ ដោយមិនមានការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅឡើយ ហើយសហចៅក្រមស៊ើបអង្កេតនឹងបន្តប្រឆាំងនឹងរាល់ការប៉ុនប៉ងជ្រាតជ្រែកនានា ក៏ដូចជាប្តេជ្ញាចិត្តការពារឯករាជ្យភាពតុលាការ ប្រឆាំងនឹងរាល់ការជ្រៀតជ្រែកពីសំណាក់ខាងក្រៅទោះបីជាមកពីមជ្ឈដ្ឋានណាក៏ដោយ។